# ទំព័រអក្សរសាស្ត្រ

## (បញ្ហាភាសាជាតិ)

បញ្ហាប្រើភាសាជាតិក្នុងការសិក្សាជាតិ ជាបញ្ហាប្រកបដោយភាពបន្ទាន់បំផុត ។

តើយើងត្រូវប្រើភាសាជាតិក្នុងការសិក្សាជាតិឬទេ ?

យើងគ្រាន់តែទឹកទៅពាក្យ «ភាសាជាតិនឹងការសិក្សាជាតិ» ដែលយើងបានប្រើក្នុងឃ្លាខាងលើនេះ យើងរកឆ្លើយថាទេមិនរួចឡើយ ។ បើការសិក្សាជាតិមិនប្រើភាសាជាតិទេ ចុះហៅថាការសិក្សាជាតិម្ដេចបាន ? តែនៅមានបងប្អូនរួមជាតិជាច្រើនបារម្ភ ក្រែងប្រើភាសាជាតិក្នុងការសិក្សាយើងមិនកើតព្រោះ :

ក - ខ្លាចក្រែងដំរេះនៃសិស្សយើងអន់ថយ បើប្រើភាសាជាតិទៅ

ខ - ខ្លាចក្រែងខ្វះសៀវភៅជាភាសាខ្មែរយើង

គ - ខ្លាចក្រែងខ្វះគ្រូខ្ពស់ៗ

ឃ - ខ្លាចក្រែងខ្វះសាលាឲ្យកូនរៀនដល់ទៅថ្នាក់ខ្ពស់ៗទៀត បងប្អូនរួមជាតិដែលបានចិញ្ចឹមសេចក្ដីបារម្ភនេះជាការប្រសើរមួយហើយ ព្រោះ

សុទ្ធតែជាអ្នកគិតទៅប្រយោជន៍ជាតិទាំងអស់ គឺថាខ្លាចក្រែងនិស្សិតខ្មែរដែលចេញពីសាលាខ្មែរ មិនប្រកបដោយវិជ្ជាជ្រៅជ្រះស្មើនឹងវិជ្ជាបរទេស ។ ខ្លាចក្រែងយុវជនយើងមិនចេះបំពេញការងារជាសាធារណៈ ដូចយុវជនជាតិឯទៀត ៗ ។ តែបើដញ្ញឹងឲ្យមែនទែនទៅឃើញថា សេចក្តីបារម្ភនេះដែលកើតឡើងដោយសារយកភាសាខ្មែរមកប្រើ ទៅជាប្រចាំងនឹងប្រយោជន៍ជាតិ ហើយប្រែត្រឡប់ទៅជាការពារប្រយោជន៍បរទេសឬការពារប្រយោជន៍ជនភាគតិចខ្លះទៅវិញ ។

សូមបងប្អូនជ្រាបថា កិច្ចបង្ខំរបស់បារាំងឲ្យយើងរៀនជាភាសាជាតិគេនោះជាអំពើជិះជាន់មួយក្តៅក្រហាយបំផុតលើប្រជាជនខ្មែរយើង ។ ចុះបើឥឡូវស្រុកយើងរួចពីកណ្តាប់ដៃគេហើយ តើនៅប្រើជាភាសាគេដល់ណាទៀត?

អ្នកខ្លះឆ្លើយថា ខ្មែរមិនមែនចង់ធ្វើបាបខ្មែរនោះទេ តែយើងបារម្ភក្រែងជំរេះនិស្សិតយើងដុនដាប ទើបមិនហានយកភាសាខ្មែរមកបង្រៀនជាភាសាសំខាន់នោះ ។ យកភាសាខ្មែរមកប្រើ ធៀបដូចលោតពីទីមួយដែលធ្លាប់ស្គាល់ធ្លាប់ស្រួលទៅទីមួយងងឹតស្ងុន ។ នេះក្រែងនាំឲ្យវង្វេង នាំឲ្យខូចការសិក្សាយើង ។ យើងសូមឆ្លើយថា បើទុកភាសាបារាំងជាភាសាសំខាន់ដដែល ជំរេះនិស្សិតខ្មែររិតតែអន់ថយ ជាងប្រើភាសាយើងទៅទៀត ហើយ

ប្រជាជនខ្មែរទូទៅនៅងងឹតដដែល ព្រោះរកសៀវភៅជាភាសាជាតិមើលមិនបាន ដូចកាលជំនាន់បារាំងអញ្ចឹង ។

ព្រោះអ្វីបានជាការសិក្សាយើងដុនដាបបើយើងនៅប្រើភាសាបារាំង ?

បើយើងប្រើភាសាបារាំងជាភាសាសំខាន់ យើងនៅតែពឹងសាស្ត្រាចារ្យបារាំងមកបង្រៀនដូចជាន់មុន ។ យើងសូមជំរាបថា ក្នុងពេលឥឡូវនេះសាស្ត្រាចារ្យបារាំងបង្រៀនមិនសូវបានផលទេ ព្រោះរដ្ឋាភិបាលបារាំងគេបញ្ជូនមកឲ្យយើងតែបុគ្គលណាដែលមានសមត្ថភាពស្តួចស្តើង ហើយគេពិនិត្យមតិនយោបាយទៀតផង ។ សាស្ត្រាណាដែលមានឆន្ទៈល្អចង់បណ្តុះបណ្តាលយុវជនខ្មែរមែនទែនគេមិនសូវឲ្យមកទេ ។ ម្យ៉ាងទៀតវិជ្ជាខាងភាសាបារាំងរបស់សិស្សយើងសព្វថ្ងៃទន់ខ្សោយណាស់ គ្មានគេស្តាប់សំដីគ្រូបារាំងមិនបានផង ។ ដោយហេតុស្តាប់មិនយល់អ្វី ដោយហេតុគ្រូបារាំងដែលមានសមត្ថភាពស្តួចស្តើងនោះ គេពន្យល់មិនបានក្បោះក្បាយ សេចក្តីសៅហ្មងកើតមានឡើងក្នុងចិត្តសព្វខ្លួន ។ គ្រូបារាំងត្អូញត្អែរថាសិស្សខ្សោយពេក សេចក្តីអស់សង្ឃឹមក៏ធុញទ្រាន់នឹងបង្ហាត់ ចូលក្នុងថ្នាក់ធ្វើការខ្ជីខ្ជាឲ្យគ្រប់តែពេល ។ ចំណែកសិស្សនឹកថាគ្រូមិនកើតក៏អស់សង្ឃឹមលែងចង់រៀនសូត្រ ។ ការទាស់ទែងគ្នាកើតមានឡើងក្នុងសិស្សគ្រប់រូប ដូចកាលការទាស់ទែងនេះ

កំផុះកើតទៅជាប្ដឹងផ្ដល់គ្នាក៏មាន ។ មិនតែប៉ុណ្ណោះសោតការទាស់ទែងគ្នានេះនាំឲ្យវិន័យក្នុងសាលាទាំងមូលខូចខាតអស់ ។ សិស្សលែងស្ដាប់គ្រូ លែងស្ដាប់អ្នកត្រួតត្រា គំនិតបះបោរកើតមានរហូតដល់ទៅពេលចេញផុតពីសាលាទៅទៀត ។ ដូច្នេះសាស្ត្រាចារ្យបារាំងនាំឲ្យសិស្សយើងខូចខាងផ្លូវចិត្តផងខាងផ្លូវបញ្ញាផង ។

មួយទៀតដោយហេតុថា «បារាំងមិនបារាំងខ្មែរមិនខ្មែរនេះ» ការសិក្សាខ្មែរអន់ថយបន្តិចម្ដងៗ ដំរេះទិសត្រឹងទីដំរេះប្រជាជនខ្មែរទូទៅកាន់តែដុនដាបបន្តិចម្ដងៗ ។ អំណើសតទៅសេចក្ដីសង្ឃឹមថា នឹងមានទិស្សែខ្មែរដែលបានជាប់សញ្ញាបត្រធំៗឯស្រុកបារាំងមកធ្វើសៀវភៅជាភាសាខ្មែរ ឬមកធ្វើគ្រូៗ សេចក្ដីសង្ឃឹមនោះរលត់សូន្យឈឹង ព្រោះសិស្សបេះៗនោះត្រូវឡប់ជាប៉ែញឹមគំនិតបង់មានបង់ធំបោះបង់ចោលការឧបត្ថម្ភ ដល់អក្សរជាតិ ៖ ដូច្នេះអនាគតរបស់វប្បធម៌ខ្មែរបានជាមិនទូលំទូលាយសោះឡើយ ។

សមត្ថភាពគ្រូខ្សោយ គ្រូបារាំងខ្លះមិនព្រមរវល់នឹងបង្រៀនឲ្យស្រួលបួលផង សមត្ថភាពសិស្សខ្មែរខ្សោយខាងភាសាបារាំង នេះនាំឲ្យការសិក្សាយើងរួញបន្តិចម្ដងៗ ។ យុវជនខ្មែររអ៊ូរទាំរកកម្លាំងនឹងរៀនមិនកើតគ្មានចេះដំរេះអ្វីជ្រៅជ្រះ ។ ហេតុនេះបានជាយើងត្រូវគិតទៅអនាគតរបស់

ការសិក្សាយើង ។ ធ្វើដូចម្ដេចឲ្យអនាគតនៃការសិក្សាយើងប្រកបទូវសេចក្ដីសង្ឃឹមខ្ពះផង ?

បើយើងទុកភាសាបារាំងជាភាសាសំខាន់ សិស្សយើងរឹតតែអន់ខ្សោយទៅទៀត យើងត្រូវតែយកភាសាខ្មែរមកប្រើជាផ្លូវការក្នុងសាលាយើង ហើយត្រូវតែយកមកប្រើក្នុងពេលឆាប់ៗនេះ ព្រោះក្នុងពេលឥឡូវនៅមានខេមរៈជនជាច្រើន គ្រូខ្មែរជាច្រើនដែលចេះភាសាបារាំងយ៉ាងស្ទាត់ ។ លោកអស់នេះមិនសូវប្រកបទូវវិជ្ជាសាស្ត្រជ្រៅជ្រះមែនហើយ ព្រោះបារាំងគេច្រើនឲ្យរៀនតែភាសាសម្រាប់ធ្វើជា «ចិបក» តែដោយចេះភាសាបារាំងជ្រៅជ្រះ លោកអស់នោះអាចនឹងទៅក្រេបយកវិជ្ជាសាស្ត្រពីគម្ពីរបារាំង ឬពីមហាវិទ្យាល័យបារាំងមកបកប្រែជាភាសាខ្មែរ ឬក៏មកបង្រៀនជាភាសាខ្មែរឲ្យកូនខ្មែរស្រួលស្ដាប់ស្រួលយល់បាន ។ តែបើមិនប្រើភាសាខ្មែរជាប្រញាប់ទេ យូរបន្តិចទៀតកូនខ្មែរចេះភាសាបារាំងតិចទៅៗមិនអាចទៅក្រេបយកវិជ្ជាសាស្ត្រធំៗបានទៀត ទុកជារាជការបញ្ជូនទៅច្រើនយ៉ាងណាក៏ដោយក៏មិនអាចទៅយល់ការបិក្សាជាភាសាគេ ឲ្យបានដូចគេអ្នកចេះភាសានោះបានឡើយ ។ បើដូច្នោះហើយទៅពេលក្រោយយើងនឹងលែងមានគ្រូខ្មែរតែហូត លែងមានសៀវភៅខ្មែរតែហូត បើមានក៏មានតែសៀវភៅ

កំទេចកំទីរដូចសព្វថ្ងៃនេះ ។ ដំរេះរបស់ប្រជាជនខ្មែរក៏រៀវរួញទៅ រកតែអ្នកកសាងជាតិឲ្យមានសមត្ថភាពមាំមួនមិនបាន ។

សង្ខេបមកយើងយល់ថា ទុកភាសាបារាំងជាផ្លូវការក្នុងការសិក្សាយើងក្នុងកាលៈទេសៈឥឡូវ នាំឲ្យការសិក្សាខ្មែរអន់ថយ បំបិទអនាគតនៃការសិក្សាយើងទៀត ។ យើងត្រូវយកភាសាជាតិមកប្រើក្នុងពេលឆាប់ៗនេះ ត្រូវគ្រូខ្មែរដែលមានសមត្ថភាពគ្រាន់បើមកបង្រៀនជំនួសបារាំង បញ្ជូនគ្រូខ្លះឲ្យទៅបំពេញវិជ្ជាឯមហាវិទ្យាល័យស្រុកបារាំងបណ្តើរៗ ឲ្យបកប្រែសៀវភៅភាសាខ្មែរបណ្តើៗ ។ ដែលធ្វើយ៉ាងនេះបាន ហើយកុំឲ្យការសិក្សាយើងដុនដាបពេក ទាល់តែខំ គ្រូក៏ត្រូវខំ រដ្ឋាភិបាលក៏ត្រូវខំ ។ រដ្ឋាភិបាលត្រូវបំណាយប្រាក់ឲ្យច្រើនបន្តិចទៅ បំពោះក្រសួងសិក្សាធិការទើបបាន ។ យើងក៏ដឹងដែរថា ប្រាក់ថវិកាជាតិខ្វះខាតជាច្រើនក្នុងពេលឥឡូវ តែបើចង់ឲ្យប្រុកយើងដើរទៅកាន់សេចក្តីចំរើន យើងត្រូវតែខំ ហាងការសិក្សាបន្តិច ។ សព្វថ្ងៃយើងឃើញថា បំណាយរបស់រដ្ឋាភិបាលបំពោះទៅក្រសួងសិក្សាធិការមានប្រហែលតែ ៨ នៃថវិកាជាតិយើងប៉ុណ្ណោះ ចំនួននេះស្តួចស្តើងណាស់ បើយើងធៀបទៅស្រុកគេឯទៀតស្រុកគេឯទៀត ដូចជាស្រុកអង់គ្លេស ២២% សហរដ្ឋអាមេរិក ២១ ស្រុកចិនប្រជា

មាទិត្យ ១៤% ។ល។

ដូច្នេះគួរតែយើងខំបន្តិចដើម្បីនឹងឲ្យការសិក្សាយើងមានដំណើរលឿនលឿន ដំបូងបង្អស់ខំប្រឹងយកភាសាខ្មែរមកប្រើក្នុងការសិក្សាខ្មែរឲ្យបាន យកបុគ្គលិកខ្មែរឲ្យធ្វើការក្នុងការសិក្សាខ្មែរ យកបញ្ហាខ្មែរឲ្យសិស្សខ្មែររៀនដោះស្រាយ ។ល។

---

## មិនមែនខុសពីគាត់ទេ !

ពូមែនទៅផ្សារបានទិញសត្វសេកមួយ ផ្ញើមកឲ្យមីងសៅជាប្រពន្ធ ។ ដល់ថ្ងៃត្រង់ គាត់ត្រឡប់មកផ្ទះវិញសួរទៅមីងសៅថា :

–ឯណាសេកដែលអញផ្ញើមកឲ្យ ?

–អញប្រឡាក់អំបិលអាំងទុកឲ្យឯងហូបបាយ

–អាំងទៅហើយ ! ឯងឡប់ខួរដែរឬ ? សេកនោះចេះនិយាយផង !

–បើអីចឹងមេចក៏វាមិនថាអីមួយអឺះសោះ កាលអញរៀបប្រឡាក់អំបិល ?

X

X X

ក. 203

ឆ្នាំទី ១

លេខ ៥

ទស្សនាវដ្ដីចេញរាល់ខែ

ក 203

ថ្ងៃ១ មករា ឆ្នាំ ១៩៥៧